# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ អញ្ជើញជាអធិបតី ក្នុងពិធីប្រកាស តែងតាំងមុខតំណែងប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្ត កែប




នៅព្រឹកថ្ងៃទី២២ ខែ មីនា ឆ្នាំ២០១៤ នៅសាលាខេត្តកែប មានរៀបចំពិធីប្រកាសតែងតាំងមុខតំណែងប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកែប ក្រោមអធិបតីភាព ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយមានការចូលរួម ពីឯកឧត្តម **កែន សត្ថា** អភិបាលនៃគណៈអភិបាល ខេត្តកែប ប្រតិភូជាថ្នាក់ដឹកនាំ និងមន្ត្រីជំនាញក្រោមឱវាទក្រសួងឧស្សាហកម្ម និងសិប្បកម្ម តំណាងអាជ្ញាធរខេត្ត តំណាងមន្ទីរអង្គភាពជុំវិញខេត្ត និងមន្ត្រីរាជការនៃមន្ទីរឧស្សាហកម្ម ខេត្ត ជាច្រើនរូបទៀត ។







ជាកិច្ចចាប់ផ្តើម អង្គពិធីបានស្តាប់របាយការណ៏សង្ខេបពីតំណាងមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកែប ស្តីពីសកម្មភាពការងារទូទៅរបស់មន្ទីរ ដោយបានលើកឡើងពីរចនាសម្ព័ន្ធមន្ទីរ-ការងាររដ្ឋបាល បុគ្គលិក-ការងារគណនេយ្យ និងហិរញ្ញវត្ថុ-ការងារវិស័យឧស្សាហកម្ម និងសិប្បកម្ម-ការងាររដ្ឋាករទឹកស្អាត-ការងារស្ថិតិស្រែអំបិល-ការងារមាត្រាសាស្ត្រ -បញ្ហាប្រឈម និងលំបាក ព្រមទាំងសំណូមពរផងដែរ ។

បន្ទាប់ពីឯកឧត្តម **អ៊ុំ សុថា** នាយកខុទ្ទកាល័យនិងជាអគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានអានប្រកាសលេខ:០៩៨ MIH/2014 ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ដែលបានសម្រេចប្រគល់ភារកិច្ចដល់លោក **ណុប វីរៈ** ជាប្រធាមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកែប រួចមក លោក **ណុប វីរៈ** បានឡើងទទួលសេចក្តីប្រកាស ស្តីពីការតែង តាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ពីឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ព្រមទាំងបានធ្វើការប្តេជ្ញាចិត្ត យ៉ាងមុតមាំ ដើម្បីឆ្លើយតប និងការផ្តល់ទំនុកចិត្ត របស់ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** គណៈអភិបាលខេត្ត និង ក្រុមប្រឹក្សាខេត្ត ដោយបានសន្យាថា:នឹងខិតខំប្រមូលនូវកម្លាំងកាយ បញ្ញា ស្មារតី និងបទពិសោធន៏ ដែលមានកន្លងមក ធ្វើជាមូលដ្ឋាន ក្នុងការសម្របសម្រួល ចាត់ចែងការងារ មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានល្អប្រសើរ ។

បន្ទាប់ពីឯកឧត្តម **កែន សត្ថា** អភិបាលនៃគណៈអភិបាលខេត្ត កែប បានឡើងធ្វើគារវៈកិច្ចនិងអបអរសាទរ ព្រមទាំងលើកឡើងពីស្ថានភាពទូទៅរបស់ខេត្តទាក់ទងនិងការងារអភិវឌ្ឍន៍ កិច្ចការពារសណ្តាប់ធ្នាប់សាធារណៈ ការងារសេដ្ឋកិច្ច ផលិតកម្ម ឧស្សាហកម្ម និងការងារទេសចរណ៍ខេត្ត ជាពិសេសបង្ហាញពីមោទនៈភាពរបស់ខេត្តកែប ដែលទទួលផ្កាដួល០២ ទង ក្នុងចលនាប្រលងប្រណាំងទីក្រុងស្អាតទទូទាំងប្រទេស ដែលលេខ១ ទទួលបាន៤ ឃុំ សង្កាត់ និងលេខ២ ទទួលបាន០១ សង្កាត់រួចមក



ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានអញ្ជើញមានមតិសំណេះសំណាល ដោយបាន សំដែងនូវការកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែង និងការដឹកនាំរបស់អជ្ញាធរខេត្តគ្រប់លំដាប់ថ្នាក់ ធ្វើឱ្យខេត្តកែបមាន ការរីកចម្រើនយ៉ាងឆាប់រហ័ស ទទួលបានចំណាត់ថ្នាក់ក្នុងចលនាប្រលងប្រណាំងទីក្រុងស្អាត និងមានកំណើនទេសចរណ៍ ជាតិ-អន្តរជាតិយ៉ាងគំហុកផងដែរ ។ ឯកឧត្តម បាន អបអរសាទរចំពោះលោក ណុប វីរៈ ដែលត្រូវបានប្រគល់ភារកិច្ចថ្មីជាប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកែប ដោយលោក ណុប វីរៈ ជាអតីតៈអនុប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល គឺជាមន្ត្រី នៅទីនេះស្រាប់ មានបទពិសោធន៍យូរឆ្នាំ សង្ឃឹមថាៈកិច្ចការគ្រប់គ្រង ដឹកនាំមន្ទីរមានដំណើរការកាន់តែល្អប្រសើរ និងមាន ភាពរលូនទៅមុខ ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបញ្ជាក់ថាៈថ្វីត្បិតតែ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បង្កើតឡើងនៅ លើមូលដ្ឋាននៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលជាក្រសួងចាស់ស្រាប់ ប៉ុន្តែតម្រូវឱ្យមានការរៀបចំជាថ្មីនូវច្បាប់ អនុក្រឹត្យ ដែលកំណត់ឡើងវិញនូវមុខងារ ភារកិច្ច បេសកកម្ម ព្រមទាំង ចាំបាច់ត្រូវកែសម្រួលរចនាសម្ព័ន្ធឡើងវិញដែរ (រាប់ទាំងឈ្មោះមន្ទីរ និងត្រាមូល) ។ ដូច្នេះ ត្រូវមានការតែងតាំងជាថ្មី មានលក្ខណៈ

ព្រមៗគ្នានូវប្រធានមន្ទីរគ្រប់ខេត្ត ទូទាំងប្រទេសសម្រាប់អណត្តិការងារថ្មីនេះ ។ ទន្ទឹមនឹងរៀបចំតួនាទី ភារកិច្ចរបស់នាយកដ្ឋាននានា ក្រសួងកំពុងរៀបចំ ប្រកាសថ្មីសម្រាប់ដំណើរការការងាររបស់មន្ទីរ ដោយគ្រោងឱ្យមាន ការិយាល័យចំនួន០៤ ចំណុះមន្ទីរគឺៈ**១**-ការិយាល័យ កិច្ចការទូទៅ **២**-ការិយាល័យកិច្ចការឧស្សាហកម្ម **៣**-ការិយាល័យ ស្តង់ដារ និងមាត្រាសាស្រ្ត និង **៤**-ការិយាល័យ ទឹកស្អាត ។ ទាក់ទង និងការយាល័យជំនាញខាងលើ ដូចជាៈការិយាល័យ ស្តង់ដារ និងមាត្រាសាស្រ្ត ឯកឧត្តម ទេសរដ្ឋមន្ត្រី បានរំលឹកថាៈការិយាល័យនេះ ត្រូវមានកិច្ចការងារច្រើន ក្នុងការចុះត្រួតពិនិត្យនូវឧបករណ៏រង្វាស់រង្វាល់ ដូចជាៈកុងទ័រទឹក-ជញ្ជីញថ្លឹង-ពិនិត្យសុក្រឹតភាពនៃចំណុះប្រេងសាំងតាមស្ថានីយ៏ប្រេងនានា និងពិនិត្យការគោរពស្តង់ដាម្ហូបអាហារជាដើម ។ ជាមួយគ្នានេះ ការិយាល័យឧស្សាហកម្មក៏មានភារកិច្ចការចុះពិនិត្យ ជាក់ស្តែងដល់ទីតាំងរោងចក្រ និងការចុះបញ្ជីឱ្យអស់នូវសហគ្រាសខ្នាតតូច និងមធ្យមដែលមាន១០៦ មូលដ្ឋាន ក្នុង ទូទាំងខេត្ត ដើម្បីឱ្យសហគ្រិនទាំងអស់នោះ ក្លាយជានីតិបុគ្គល និងងាយស្រួលក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៏ ។ ដោយ ឡែកទាក់ទង និងការងារទឹកស្អាត ឯកឧត្តមទេសរដ្ឋមន្រ្តី បានបញ្ជាក់ថាៈខេត្តកែបត្រូវបានសម្តេចតេជោ នាយករដ្ឋមន្ត្រី ប្រគល់ភារកិច្ចឱ្យរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញរៀបចំបណ្តាញទឹកស្អាតនៅទីនេះ ដែលបច្ចុប្បន្នផ្នែករដ្ឋាករទឹកបានធ្វើការ សិក្សានូវលទ្ធភាពជាច្រើនដែលដំណាក់កាលដំបូងគឺពនិត្យលទ្ធភាពការខួងអណ្តូងយកទឹកក្រោមដី ដើម្បីផ្គត់ផ្គង់ទឹកស្អាតហើយឯកឧត្តម បានស្នើឱ្យពន្លឿនកិច្ចការនេះ ពីព្រោះការផ្គត់ផ្គង់ទឹកស្អាត នឹងជួយឱ្យខេត្តកែបទទួលបាននូវកំរិតអភិវឌ្ឍន៏ថែមទៀត ។ ទាក់ទងនិងការងារស្រែអំបិល ឯកឧត្តម បានបង្ហាញនូវកង្វល់ និងស្នើឱ្យមានការយកចិត្តទុកដាក់លើបញ្ហាគ្រប់គ្រងស្រែអំបិលឱ្យបានហ្មត់ចត់ ជាពិសេសគឺផ្ទៃដីស្រែអំបិល ក្នុងសហគមន៏អ្នកផលិតអំបិលខេត្តកំពត និងកែប ដោយមិនត្រូវបោះបង់ការផលិត រឺកែប្រែប្រភេទដីទៅជាមុខសញ្ញាអាជីវកម្មផ្សេងឡើយ ហើយក្រសួងនឹងចុះពិនិត្យស្វែងយល់និងវាយតម្លៃពីការគ្រប់គ្រងរបស់សហគមន៏ស្រែអំបិលនៅពេលខាងមុខ ។ ចំពោះបញ្ហាកំពុងជួបការ លំបាក និងមានសំណូមពរមានដូចជាៈបញ្ហាធុនធានមនុស្ស និងកង្វះមន្ត្រីរាជការ-ទីកន្លែងធ្វើការ-ថវិការដំណើរការ និងការ បំពាក់សម្ភារៈជាដើម ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានទទួលស្គាល់ថាៈពិតជាមានការលំបាក ក្នុងពេលដែលយើងបំបែកមន្ទីរចាស់មួយទៅជាមន្ទីរថ្មីពីរ ។ ទោះជាយ៉ាងណាក្រសួងនឹងខិតខំ រិៈរកមធ្យោបាយ ដោះស្រាយការលំបាកនេះជាបណ្តើរៗ ។

បន្ទាប់មក ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ឯកឧត្តម អភិបាលខេត្ត **កែន សត្ថា** និង ប្រតិភូអមដំណើរ បានអញ្ជើញចុះពិនិត្យមើលទីតាំងក្នុងផែនទី ក្នុងការកំណត់តំបន់ខួងយកទឹកក្រោមដី ដែលស្ថិត ក្នុងភូមិថ្មី ជិតអាងស្តុកទឹកចាស់ ព្រមទាំងអញ្ជើញចុះពិនិត្យមើលមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកែបផងដែរ ។



